រាជបណ្ឌិត្យសភាកម្ពុជា

# លក្ខណៈសន្ធិបាលីក្នុងភាសាខ្មែរ

គឿន ប៊ុនលាង

សារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ : ភាសាវិទ្យា

២០២១

រាជបណ្ឌិត្យសភាកម្ពុជា

# លក្ខណៈសន្ធិបាលីក្នុងភាសាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ....00293 1
រាជបណ្ឌិត្យសភាកម្ពុជា

គឿន ប៊ុនលាង

សាស្ត្រាចារ្យណែនាំ : បណ្ឌិត ជួរ គារី

សារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ : ភាសាវិទ្យា

២០២១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**រាជបណ្ឌិត្យសភាកម្ពុជា**

Royal Academy of Cambodia
Académie Royale du Cambodge

**លេខ : ០០៩ / ២០ ស.ស.រ.**

# សេចក្តីសម្រេច
## ស្តីពី
## ការអនុញ្ញាតឱ្យការពារបញ្ចប់និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី មាត្រា១០ថ្មី មាត្រា១១ថ្មី មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ១១ ស.ស.រ. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្របង់ថ្លៃសិក្សាស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងគោលការណ៍ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងចំណារឯកភាពរបស់សាស្ត្រាចារ្យណែនាំ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០

**សម្រេច**

**ប្រការ ១** : អនុញ្ញាតឱ្យលោក **គឿន ម៉ុនលាង** និស្សិត**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៥ វគ្គ១** ជំនាញ **ភាសាវិទ្យា** ការពារបញ្ចប់និក្ខេបបទនៅថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២០ ។

**ប្រការ ២** : គណៈកម្មការវាយតម្លៃនិក្ខេបបទ ផ្នែកបណ្តុះបណ្តាលនិងស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២០
**ប្រធាន**

បណ្ឌិតសភាចារ្យ **សុខ ទូច**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខ : ០២៩ / ២០ ឧ.ឧ.ន.

# លិខិតឧទ្ទេសនាម
## គណៈកម្មការវាយតម្លៃការការពារបញ្ចប់និក្ខេបបទ
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| ល.រ. | គោត្តនាម និង នាម | ជំនាញ | តួនាទី |
|---|---|---|---|
| ១ | បណ្ឌិត **ខន្ធ មេង** | ភាសាវិទ្យា | ប្រធាន |
| ២ | បណ្ឌិត **ជួរ គារី** | ភាសាវិទ្យា | សាស្ត្រាចារ្យណែនាំ |
| ៣ | បណ្ឌិត **ជុំ ស៊ុនណាង** | ភាសាវិទ្យា | សមាជិក |
| ៤ | បណ្ឌិត **មាឃ ប៉ូរ៉ា** | ភាសាវិទ្យា | សមាជិក |
| ៥ | បណ្ឌិត **ប៊ី សុខគង់** | ភាសាវិទ្យា | សមាជិក |

- និស្សិត : **គឿន ប៊ុនលាង** - ភេទ : ប្រុស
- ជំនាញ : **ភាសាវិទ្យា** - **ជំនាន់ទី៥ ខត្ត១**
- ប្រធានបទ : **លក្ខណៈសន្ធិបាលីក្នុងភាសាខ្មែរ**
- សាស្ត្រាចារ្យណែនាំ : បណ្ឌិត **ជួរ គារី**
- កាលបរិច្ឆេទការពារ : ថ្ងៃទី ៤ ខែ មេសា ឆ្នាំ២០២០ - ម៉ោង : ៩:០០ នាទី

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០
ប្រធាន

បណ្ឌិតសភាចារ្យ **សុខ ទូច**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានបទ៖ លក្ខណៈសន្ធិបាលីក្នុងភាសាខ្មែរ**

គណៈកម្មការវាយតម្លៃសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញ ភាសាវិទ្យា

សូមបញ្ជាក់ថា៖ និស្សិត **គឿន ម៉ុនលាង**

ពិតជាបានការពារសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បញ្ចប់ដោយជោគជ័យនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២០ ពិតប្រាកដមែន។

១- សាស្ត្រាចារ្យបណ្ឌិត **វង្ស មេង** ប្រធានគណៈកម្មការ

២- សាស្ត្រាចារ្យបណ្ឌិត **ជូរ គារី** សាស្ត្រាចារ្យណែនាំ

៣- សាស្ត្រាចារ្យបណ្ឌិត **ជុំ ស៊ុនលាង** សមាជិក

៤- សាស្ត្រាចារ្យបណ្ឌិត **មាឃ បូរ៉ា** សមាជិក

៥- សាស្ត្រាចារ្យបណ្ឌិត **ប៊ី សុខគង់** សមាជិក

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

**អគ្គលេខាធិការរង**

**ទទួលបន្ទុកមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ**

**សូត្រ សំណាង**

# មាតិកា

ឧទ្ទិសកថា.............................................................................................ក
សេចក្តីថ្លែងអំណរគុណ.............................................................................ខ
អំណះអំណាង.........................................................................................គ
អារម្ភកថា...............................................................................................ឃ

## សេចក្តីផ្តើម

១- លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ................................................................... ១
២- ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ................................................................ ១
៣- គោលបំណងនៃការសិក្សាស្រាវជ្រាវ.....................................................................២
៤- ដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ...................................................២
៥- វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ......................................................................... ៣
៦- សារប្រយោជន៍នៃការសិក្សាស្រាវជ្រាវ................................................................. ៣
៧- រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ........................................................................៤

## ជំពូកទី១
## រំព្ញកទ្រឹស្តី

១.១- សន្ធិ ...................................................................................................៥
១.២- ឧបករណ៍សម្រាប់ការតភ្ជាប់..........................................................................៥
១.៣-ប្រធានសន្ធិ.................................................................................................៦
១.៣.១ ការតដោយស្រះ...........................................................................៦
១.៣.២ ការតដោយព្យញ្ជនៈ......................................................................៧
១.៣.៣ ការតដោយនិគ្គហិត.......................................................................៧
១.៤- ទស្សនៈអ្នកប្រាជ្ញនានាទៅលើសន្ធិ ....................................................................៨

## ជំពូកទី២
## ពាក្យដែលតភ្ជាប់ដោយសន្ធិបាលី

២.១- ពាក្យតដោយស្រះ ...................................................................................១៣
២.១.១- ការតដោយលុបស្រះ..........................................................................១៣
ក- ការតដោយលុបស្រះខាងដើម........................................................................១៣

ខ- ការតដោយលុបស្រៈខាងចុង.......................................................................១៤

២.១.២- ការតដោយផ្លាស់ស្រៈជាព្យញ្ជនៈ.............................................................១៥

ក- ការតដោយផ្លាស់ស្រៈខាងដើមជាព្យញ្ជនៈ.............................................១៥

ខ- ការតដោយផ្លាស់ស្រៈខាងចុងជាព្យញ្ជនៈ..............................................១៦

២.១.៣- ការតដោយចុះស្រៈអាគម........................................................................១៦

២.១.៤- ការតដោយផ្លាស់ស្រៈជាស្រៈផ្សេង...........................................................១៧

ក- ការតដោយផ្លាស់ស្រៈខាងដើមជាស្រៈផ្សេង.........................................១៧

ខ- ការតដោយផ្លាស់ស្រៈខាងចុងជាស្រៈផ្សេង...........................................១៨

២.១.៥- ការតដោយទុកស្រៈឱ្យនៅដូចដើម.........................................................១៨

២.១.៦- ការតដោយធ្វើស្រៈខ្លីជាស្រៈវែង................................................................១៩

ក- ការតដោយធ្វើស្រៈខ្លីខាងដើមជាស្រៈវែង................................................១៩

ខ- ការតដោយធ្វើស្រៈខ្លីខាងចុងជាស្រៈវែង..................................................២០

២.១.៧- ការតដោយធ្វើស្រៈវែងជាស្រៈខ្លី................................................................២១

ក- ការតដោយផ្លាស់ស្រៈសិន ទើបស្សេះ......................................................២១

ខ- ការតដោយស្សេះស្រៈខាងដើម...............................................................២២

២.២- ពាក្យតដោយព្យញ្ជនៈ.................................................................................២២

២.២.១- ការតដោយលុបព្យញ្ជនៈ..........................................................................២២

២.២.២- ការតដោយផ្លាស់ព្យញ្ជនៈជាព្យញ្ជនៈផ្សេង..................................................២៣

២.២.៣- ការតដោយចុះព្យញ្ជនៈអាគម....................................................................២៤

២.២.៤- ការតដោយទុកព្យញ្ជនៈដូចដើម................................................................២៥

២.២.៥- ការតដោយតម្រួតព្យញ្ជនៈ.......................................................................២៦

ក- ការតដោយតម្រួតព្យញ្ជនៈដែលមានរូបដូចគ្នា.......................................២៦

ខ- ការតដោយតម្រួតព្យញ្ជនៈដែលមានរូបមិនដូចគ្នា...................................២៦

២.៣- ពាក្យតដោយនិគ្គហិត.................................................................................២៧

២.៣.១- ការតដោយលុបនិគ្គហិត..........................................................................២៧

២.៣.២- ការតដោយផ្លាស់និគ្គហិតជាព្យញ្ជនៈ..........................................................២៨

២.៣.៣- ការតដោយចុះនិគ្គហិតអាគម... ..........................................................២៩

២.៣.៤- ការតដោយទុកនិគ្គហិតឱ្យនៅដូចដើម..........................................................៣០

## ជំពូកទី៣

## ការសិក្សាវិភាគទៅលើការប្រើប្រាស់សន្ធិ

៣.១- **វិធីតដោយស្រៈ**..........................................................................................៣១

៣.១.១- វិធីតដោយលុបស្រៈ.........................................................................៣១

ក- វិធីតដោយលុបស្រៈខាងដើម..............................................................៣១

ខ- វិធីតដោយលុបស្រៈខាងចុង...............................................................៣៦

៣.១.២- វិធីតដោយផ្លាស់ស្រៈជាព្យញ្ជនៈ........................................................ ៣៧

ក- វិធីតដោយផ្លាស់ស្រៈខាងដើមជាព្យញ្ជនៈ............. ..................................... ៣៧

ខ- វិធីតដោយផ្លាស់ស្រៈខាងចុងជាព្យញ្ជនៈ............... .....................................៣៩

៣.១.៣- វិធីតដោយចុះស្រៈអាគម........................................................................ ៤០

៣.១.៤- វិធីតដោយផ្លាស់ស្រៈជាស្រៈផ្សេង..........................................................៤១

ក- វិធីតដោយផ្លាស់ស្រៈខាងដើមជាស្រៈផ្សេង..............................................៤១

ខ- វិធីតដោយផ្លាស់ស្រៈខាងចុងជាស្រៈផ្សេង................................................៤២

៣.១.៥- វិធីតដោយទុកស្រៈឱ្យនៅដូចដើម...........................................................៤៣

៣.១.៦- វិធីតដោយធ្វើស្រៈខ្លីជាស្រៈវែង ............................................................ ៤៤

ក- វិធីតដោយធ្វើស្រៈខ្លីខាងដើមជាស្រៈវែង.................................................. ៤៤

ខ- វិធីតដោយធ្វើស្រៈខ្លីខាងចុងជាស្រៈវែង................................................... ៤៥

៣.១.៧- វិធីតដោយធ្វើស្រៈវែងជាស្រៈខ្លី.............................................................៤៧

ក- វិធីតដោយផ្លាស់ស្រៈសិន ទើបរស្សៈ..........................................................៤៧

ខ- វិធីតដោយរស្សៈស្រៈខាងដើម.................................................................. ៤៨

៣.២- **វិធីតដោយព្យញ្ជនៈ**........................................................................................ ៤៩

៣.២.១- វិធីតដោយលុបព្យញ្ជនៈ.......................................................................... ៤៩

៣.២.២- វិធីតដោយផ្លាស់ព្យញ្ជនៈជាព្យញ្ជនៈផ្សេង ................................................. ៥០

៣.២.៣- វិធីតដោយចុះព្យញ្ជនៈអាគម .................................................................. ៥២

៣.២.៤- វិធីតដោយទុកព្យញ្ជនៈដូចដើម ......................................................... ៥៣
៣.២.៥- វិធីតដោយតម្រួតព្យញ្ជនៈ ......................................................... ៥៦
ក- វិធីតដោយតម្រួតព្យញ្ជនៈដែលមានរូបដូចគ្នា........ ......................................................... ៥៧
ខ- វិធីតដោយតម្រួតព្យញ្ជនៈដែលមានរូបមិនដូចគ្នា......................................................... ៥៨
៣.៣- វិធីតដោយនិគ្គហិត......................................................... ៦០
៣.៣.១- វិធីតដោយលុបនិគ្គហិត......................................................... ៦០
៣.៣.២- វិធីតដោយផ្លាស់និគ្គហិត ......................................................... ៦១
៣.៣.៣- វិធីតដោយចុះនិគ្គហិតអាគម......................................................... ៦២
៣.៣.៤- វិធីតដោយទុកនិគ្គហិតដូចដើម ......................................................... ៦២
៣.៤- បម្រែបម្រួលសូរក្នុងសន្ធិ......................................................... ៦៣
៣.៥- បម្រែបម្រួលសូរដោយប្ដូរបទចុងជាបទដើម......................................................... ៦៧
៣.៦- ការកែប្រែសូរព្យញ្ជនៈរឹងមកជាព្យញ្ជនៈទន់......................................................... ៦៩
៣.៧- ការកែប្រែសូរស្រៈ......................................................... ៧០
៣.៨- វិធីអានពាក្យខ្មែរខ្ចីពីភាសាបាលី......................................................... ៧១
ក- អក្សរចុងពាក្យ......................................................... ៧១
ខ- ពាក្យសមាស......................................................... ៧២

## សេចក្ដីសន្និដ្ឋាន

- សេចក្ដីសន្និដ្ឋាន......................................................... ៧៤
- គន្ថនិទ្ទេស ......................................................... ៧៧

## ឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១៖ សទ្ទានុក្រម......................................................... (I)
- ឧបសម្ព័ន្ធទី២៖ តារាងបម្លាស់ប្ដូរស្រៈ ព្យញ្ជនៈ និងនិគ្គហិតសង្ខេប......................................................... (III)
-ឧបសម្ព័ន្ធទី៣៖ ពាក្យដែលតភ្ជាប់ដោយសន្ធិបាលី......................................................... (VII)

# មូលន័យសង្ខេប

ដើម្បីរួមចំណែកក្នុងការលើកស្ទួយអក្សរសាស្ត្រជាតិនិងបានជាគន្លងក្នុងការបង្កើតពាក្យថ្មីៗក្នុងភាសាខ្មែរយើងផងនោះ ក្នុងសារណាដែលមានប្រធានបទថា **លក្ខណៈសន្ធិបាលីក្នុងភាសាខ្មែរនេះ** គឺជាការសិក្សាពីវិធីតបទ និងបទឬពាក្យនិងពាក្យដោយផ្ដោតទៅលើវិធីនៃការបង្កើតពាក្យថ្មី ដោយខ្ចីធាតុផ្សំពីភាសាបាលី។

ការបង្កើតពាក្យខ្មែរតាមវិធីសន្ធិបាលីនេះ យើងឃើញមានធាតុដោយច្រើនគឺខ្ចីពីភាសាបាលី ឯការបង្កើតពាក្យថ្មីក្នុងភាសាខ្មែរបច្ចុប្បន្នក៏ផ្អែកលើធាតុពីភាសាបាលីជាមូលដ្ឋានដែរ។ ការបង្កើតពាក្យខ្មែរតាមបែបសន្ធិបាលីនេះ មានវិធីបង្កើត៣យ៉ាងសំខាន់ ដែលបុព្វបុរសខ្មែរយើងបានអនុវត្តរួចមកហើយគឺ ១- ការបង្កើតពាក្យដោយតស្រះនិងស្រះ ដូចជាពាក្យថា នយ + ឧបាយ > នយោបាយ, ភូមិ + ឥន្ទ > ភូមិន្ទ, ប្រជា + អាធិបតេយ្យ > ប្រជាធិបតេយ្យ, ២- ការបង្កើតពាក្យដោយតស្រះនិងព្យញ្ជនៈ មានដូចជាពាក្យថា សេដ្ឋ + កិច្ច > សេដ្ឋកិច្ច, អន្តរ + ជាតិ > អន្តរជាតិ, បរ + ទេស > បរទេស, និង៣- ការបង្កើតពាក្យដោយតនិគ្គហិតនិងស្រះ ឬតនិគ្គហិតនិងព្យញ្ជនៈ ដូចជាពាក្យថា សំ + អាគម > សមាគម, សំ + គម > សង្គម, អលំ + ការ > អលង្ការ ជាដើម។ ការបង្កើតពាក្យតាមវិធីសន្ធិនេះ បុព្វបុរសខ្មែរយើងបានប្រើ ហើយថែមទាំងបានផ្ដល់និយមន័យទាក់ទងនឹងការប្រើប្រាស់សន្ធិសម្រាប់អ្នកជំនាន់ក្រោយទៀតផង តែច្រើនធ្វើទៅតាមការយល់ឃើញរៀងៗខ្លួន។ ដោយផ្អែកលើនិយមន័យទាំងនោះ យើងបានប្រមូលចងក្រងទិន្នន័យនៃពាក្យខ្មែរជាច្រើននិងរៀបចំដាក់ទៅតាមវិធីនៃការបង្កើតពាក្យខ្មែរតាមបែបសន្ធិបាលីនីមួយៗនិងបានសិក្សាលម្អិតនៅក្នុងវិធីនីមួយៗដើម្បីរកឱ្យឃើញពីវិធីបង្កើតពាក្យខ្មែរនៃសន្ធិដែលមានប្រើក្នុងភាសាខ្មែរបច្ចុប្បន្ន។ ហេតុដូច្នេះ ទើបបានជាក្នុងប្រធានបទសារណានេះ យើងបានសិក្សាឃើញថាអត្ថន័យពិតនៃសន្ធិគឺជា វិធីត ឬវិធីតភ្ជាប់ គឺវិធីតបទនិងបទឬពាក្យនិងពាក្យឱ្យជាប់គ្នាជាពាក្យតែមួយ ដែលមានលក្ខណៈបំប្រួញព្យាង្គឱ្យតិចចុះ និងងាយស្រួលបន្លឺបានពីរោះស្ដាប់។ ពាក្យមួយដែលបង្កើតដោយវិធីតរបស់សន្ធិ ពាក្យខ្លះត្រូវប្រើវិធីមួយក៏មាន ពីរក៏មាន ឬលើសពីនេះក៏មាន អាស្រ័យលើធាតុផ្សំនៃពាក្យនោះ បើពាក្យនោះផ្សំឡើងដោយបទមានចំនួនច្រើន វិធីតក៏មានចំនួនច្រើនទៅតាមសង្កាត់នីមួយៗដែរ។ម្យ៉ាងទៀត ការសិក្សាពីសន្ធិបាលីនេះ ក៏ធ្វើឱ្យយើងយល់ពីរបៀបនៃការប្រើប្រាស់ និងរកឃើញវិធីបង្កើតពាក្យតាមបែបសន្ធិសរុបគឺមានចំនួន២២វិធី ហើយមានតែ១៥ វិធីប៉ុណ្ណោះដែលមានប្រើក្នុងភាសាខ្មែររហូតដល់បច្ចុប្បន្ននេះ ដោយឡែក នៅមានវិធីសន្ធិចំនួន៧វិធីទៀត មិនទាន់មានប្រើប្រាស់ក្នុងភាសាខ្មែរនៅឡើយ។ សារណានេះ ក៏ជួយឱ្យយើងបានយល់ដឹងពីការប្រែប្រួលសូរនៃការបន្លឺពាក្យក្នុងភាសាខ្មែរយើងផងដែរ ពីព្រោះពាក្យខ្មែរខ្លះ ក៏នៅរក្សាសូរនៃការបន្លឺដដែល ខ្លះទៀតក៏ត្រូវផ្លាស់ប្ដូរសូរនៃការបន្លឺទាំងស្រុង នៅពេលតភ្ជាប់គ្នា ដោយសារឥទ្ធិពលរបស់សន្ធិបាលី។ ម្យ៉ាងវិញទៀត ការសិក្សានេះក៏ធ្វើឱ្យអ្នកអានបានចេះដឹងពីរបៀបអានពាក្យខ្មែរដែលខ្ចីធាតុពីភាសាបាលី ថែមទាំងយល់ន័យនៃពាក្យទាំងនោះបានខ្លះផងដែរ។ ជាងនេះទៅទៀត ការសិក្សាទៅលើប្រធានបទសារណានេះ ក៏ជួយឱ្យយើង បានជាគំនិតនិងបានជាគន្លងមួយសម្រាប់យកទៅអនុវត្តបង្កើតពាក្យថ្មីៗបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការពាក្យថ្មីក្នុងភាសាខ្មែរនាពេលបច្ចុប្បន្ននិងជួយឱ្យភាសាខ្មែរយើងក្លាយទៅជាភាសាមួយសុក្រឹត្យ និងរឹងមាំលើផ្នែកវេយ្យាករណ៍។

ហេតុដូច្នេះ ក្នុងប្រធានបទសារណានេះ យើងបានសិក្សាឱ្យឃើញពីអត្ថន័យពិតនៃសន្ធិ របៀបនៃការប្រើប្រាស់ មានវិធីបង្កើតប៉ុន្មាន និងបម្រែបម្រួលសូរនៃការបន្លឺពាក្យមួយចំនួនដែលផ្លាស់ប្ដូរដោយសារឥទ្ធិពលនៃសន្ធិ។